**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...២៤៩៦៩...អពដ

L20230713021 9TD3526

ថ្ងៃ អង្គារ ៨ កើត ខែ ទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០២៣

# សេចក្ដីជូនដំណឹង
## ស្ដីពី
## បញ្ជីក្រុមហ៊ុន ឬសហគ្រាសដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ និងមានសុពលភាព

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ ដែលជាម្ចាស់សហគ្រាស ឬក្រុមហ៊ុន មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារសូមផ្តល់ជូននូវបញ្ជីឈ្មោះក្រុមហ៊ុន ឬសហគ្រាសប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលទទួលបានអាជ្ញាប័ណ្ណពីអគ្គនាយកដ្ឋានពន្ធដារ គិតត្រឹមថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ក្នុងគោលបំណងផ្តល់ព័ត៌មាន និងជួយសម្រួលដល់ការប្រើប្រាស់សេវាពាក់ព័ន្ធនឹងពន្ធដារ (បំពេញបែបបទពន្ធដារ ដាក់លិខិតប្រកាសពន្ធ បង់ប្រាក់ពន្ធប្រចាំខែ និងប្រចាំឆ្នាំជាដើម) ក៏ដូចជាចៀសវាងការប្រើប្រាស់សេវាពាក់ព័ន្ធនឹងពន្ធដារពីបុគ្គលដែលគ្មានអាជ្ញាប័ណ្ណ ដែលនាំឱ្យទទួលរងនូវការពិន័យ និងទោសទណ្ឌផ្សេងៗ។

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងប្រកាសលេខ ២៣០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ បញ្ជាក់ថា៖

១. បុគ្គលដែលប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ) ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០.០០០.០០០ រៀល (ដប់លានរៀល) ដល់ ២០.០០០.០០០ រៀល (ម្ភៃលានរៀល)

២. អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលទទួលការផ្គត់ផ្គង់សេវាកម្មពន្ធដារ ពីបុគ្គលដែលមិនមែនជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណ ត្រូវទទួលរងពិន័យជាប្រាក់ ៥.០០០.០០០ រៀល (ប្រាំលានរៀល)។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ ដែលជាម្ចាស់សហគ្រាស ឬក្រុមហ៊ុនជ្រាបជាព័ត៌មាន។

**អគ្គនាយកដ្ឋានពន្ធដារ**

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh